Khmer Story Lovers

# ១

# មគ្គុទ្ទេសក៍ក្រមុំ

រថយន្តទេសចរធំចង្រ្កាងថ្មីស្រឡាងមួយ បានលូនមកឈប់សម្ងំស្ងៀមអែបនឹងចិញ្ចើមវិថីម្ខាង ក្នុងទីប្រជុំជនស្គន់ ធ្វើឱ្យក្រុមអ្នកលក់ដូរ និងក្រុមម៉ូតូឌុប ផ្អើលឈូឆរពាក់ពពូន មកចោមក្រឡឹងយានទើបនឹងមកសំចតនេះយ៉ាងអ៊ូអែ មើលទៅហាក់គ្មានសណ្ដាប់ធ្នាប់បន្តិចណាសោះ ។

សូរសព្ទអឺងកងលាន់ទ្រហឹងដាស់ ស្ទើរតែរកស្ដាប់សម្លេងនរណាម្នាក់ឱ្យបានច្បាស់ ពុំបានឡើយ ។ ក្រុមអ្នកលក់ ខំស្រែកពពាយនាយគ្មានទំនេរមាត់ ហើយខំដើរបញ្ច្រៀតគ្នា អើតក្បាលរហង់នៅតាមចន្លោះបង្អួចរថយន្ត ។ អ្នកខ្លះទូលថាសផ្ទុកបាយកញ្ចប់ ចង់ជ្រក់ ត្រីងៀត ត្រីអាំង ពងទាស្ងោរ ប្រហុកកប់...។ អ្នកខ្លះខំទ្រថាសផ្ទុកពេញពោរនូវចង្រិតលីង អាពីង កន្ធាសទូក កន្ទេះឡង់...។ អ្នកខ្លះទៀតកណ្ដៀតល្អីលក់នំអាកោត្នោត ក្រឡាន កំពីងត្នោត គ្រាប់ត្នោត... និងរូមអ្នកដទៃទៀត ដើរខ្វៃខ្វាត់លក់ផ្លែឈើ និងគ្រឿងប្រើប្រាស់ផ្សេងៗ ក៏មកបានមូលមីរកកកុញព័ទ្ធរោមជុំជិត ដូចធ្វើឱ្យក្រុមម៉ូតូឌុបស្រែកបង្អើលកោកកាក ចំអកចំអន់មកក្រុមអ្នកលក់ទាំងនោះ ទាំងរញ៉េវរញ៉ៃរញ៉ៃក្នុងចិត្ត ។

ប្រហែលជាដឹងថា ក្រុមអ្នកទេសចរធ្វើទេសចរណ៍កម្សាន្តនេះ មិនតម្រូវការជិះម៉ូតូខ្លួន ក្រុមម៉ូតូឌុបក៏បើកយានបំបែកផ្លូវគ្នា ចេញអន្តយអស់ទៅ ដោយបានដៃមកដល់ក្រុមអ្នកលក់ដូរនៅប្រឫបផ្លូវតាមយានយន្តនានាទៅវិញ ។

ស្របពេលនោះ ទ្វារយានរបើកឡើង អ្នកទេសចរប្រុសស្រី ចាស់ក្មេងទាំងនោះ ក៏បានរូតរះម្នីម្នាដើរចុះពីយានមក ទាំងទឹកមុខស្រស់ស្រាយ ញញឹមញញែម ដោយអ្នកខ្លះបានវាចាចៅវ៉ៅមកកាន់អ្នកលក់ ហើយអ្នកខ្លះទៀត ដើរឃ្លាតទៅឆ្ងាយតាមចំណង់របស់គេ ។

បន្ទាប់មក លេចស្រស់ស្រីទងវង្សម្នាក់ កំពុងឈានជើងចុះចេញពីរថយន្ត មានរាងចង្វាមូលតូចច្រឡឹង សម្បុរសណ្តែកបាយជ្រះ ពាក់មួកកន្ទីបមានតែហាមពិណផ្កាកុលាប ដោយរីបក្តោបសំនុំសរសៃសក់ខ្មៅរលើបវែងអន្ធាយប៉ប្រះស្មា រង្វង់មុខរាងពងក្រពើ ចញ្ចើមកោងខ្មៅក្រិបដូចដងធ្នូ ភ្នែកមូលធំស្រទន់ ស័ក្តិសមនឹងផែនថ្ពាល់សរលោងឃើញសរសៃល្អិតៗក្រហមព្រឿងៗ បបូរមាត់ក្រហមព្រាលៗដូចក្លែបក្រូច មានព្រែកកណ្តាលបន្តិច ច្រមុះតូចស្រួចលេចទ្រនុងខ្ពស់ ហើយមានពាក់អាវយឺតពណ៌សដៃខ្លីរីបរាងមូលក្លំ សមនឹងដើមទ្រូងពើងងើប គួរឱ្យភ្ញាក់ក្តក់សម្លក់សម្លឹង ។ ប៉ុន្តែនាងក្រមុំបានពាក់អាវក្រៅពណ៌កាគី វៀលរក្សៀកមួយជាន់ទៀតគ្របពីលើអាវយឺតពណ៌ស ដោយចំហទ្រូង ដែលជាម៉ូតអាវសម្រាប់អ្នកដើរថតរូប និងបានស្លៀកខោខូវប៊យជើងវែងពណ៌ទឹកប៊ិចក្រមៅ រីបត្រគាកសាយណែនក្បំ ទាំងមានពាក់កាបូបក្រវាត់ចង្កេះពណ៌ក្រហមឆ្អៅ ធ្លាក់សំយ៉ែះចំពីមុខ ហើយពាក់ស្បែកជើងប៉ាតាពណ៌សដ៏ស្រស់វិចិត្រ ។

នៅពេលឃើញស្រស់តរុណី មានរូបសម្ផស្សស្រស់ល្អត្រដូចត្រដឹម ស្មើរនឹងរកលំអស្ត្រីក្នុងលោកមកប្រៀបផ្ទឹមស្មើពុំបានភ្លាម ក្រុមអ្នកលក់បែរជានាំគ្នាឈរភាំងស្រឡាំងកាំង ហាមាត់ចង្រ្កងស្មើរភ្លេចដកដង្ហើម ដោយភ្លូកភ្លឹកផ្ចត់អារម្មណ៍ ស្លុងស្លុតស្មារតី តាមផ្តោតគយគន់ផ្ទៀកៗគ្រប់ៗគ្នា ហើយគួចគិតមមៃ លបអួតសរសើរពីរូបសម្រស់នាងក្រមុំតែរៀងៗខ្លួន... " ស្រស់អ្វីក៏ស្រស់ម្ល៉េះ ព្រះជាម្ចាស់អើយ...! ឬក៏ជាទេពធីតា ចុះចាកពីឋានសួគ៌ាល័យ មកក្រសាលព្រះរាជហឫទ័យនៅឋានកណ្តាល នាផ្សារស្តន់ប្រហែលម៉ោងប្រាំបួនព្រឹកដ៏មហានក្ខត្តឫក្សនេះ...! " ។

មីងម្នាក់ឈរស្ទូក ហើយធ្វើភ្នែកស្លឹ ដោយមានមុខជាំប្រតាក សម្បុរខ្មៅក្រិត



សក់រួញក្រញាញ់បះក្រញាង ខំកណ្តៀតល្អីផ្ទុកផ្លែស្វាយចន្ទីរណ្ហូករណែល ឡើងវៀចចង្កេះក៏លបរអ៊ូធ្វើមាត់ជីបអូចៗ... " ស្អាតណាស់លោកអើយ សូម្បីតែតួសម្តែង ក៏សុំខ្មាសដែរ...! ក្មួយតូចទ្រមែរបស់មីងអើយ ក្មួយស្រស់សោភា គួរឱ្យត្រឹតត្រាញ់ខ្លាំងណាស់...! ក្មួយធ្វើបុណ្យអ្វីពីជាតិមុនទៅ ម្តេចក៏ជាតិនេះ ក្មួយស្រស់បំណាច់បែបនេះ...? ឯមីងវិញខំធ្វើបុណ្យណាស់ដែរ បែរជាមានរូបមើលមិនយល់...! បើបានប្តីវិញ ក៏កញ្ឆែបច្រមុះមាត់កញ្ជើញ សម្ពីករីកដូចមាត់ខ្យង ហើយក៏ក្រងូរទៀត...! ក្មួយពិតជារតននារី ពេញភ្នែកមីងណាស់...! " ។ ស្ត្រីរអ៊ូរង៉ូវ ហាក់ឈឺចិត្តនឹងវាសនាខ្លួន ដែលបានកើតមកមានរូបសម្បត្តិមិនស្អាតបវរ ហើយនៅតែឈរបន្តភ្លេចអស់រលីងនូវការលក់ដូរ ។

នៅខាងក្រោយក្រុមអ្នកលក់ទាំងនោះ ក៏ប្រទះឃើញនាងម្នាក់មានមាឌកន្ទ្រើ ក កន្ទុលរួញជាប់ស្មា ថ្ពាល់ធំកំពាង បានទូលថាសផ្ទុកជ្រក់ម្កាក់ ត្របែក ចំណិតស្វាយ ខ្ទិះ កំពឹងរាជ រំដេញ ពុទ្រា កន្ទួត ខំដើរអន្ទ្រើតៗឡេមឡឹមញែកគេឯងចូលមក ហើយខំត្រវីចង្កេះកន្ទុញ ទាំងភ្ញាភ្ញាក់ដោយលាន់មាត់តិចៗ... " ពិតជាកំពូលនារីគ្មានពីរ នៅលើលោកនេះមែន...! អ្នកបង ពូកែថែសម្រស់អ្វីម្ល៉េះហ្ន៎...! រូបសម្រស់អ្នកបង ស្រស់ស្អាតដូចចំប៉ីសូគ៌ាអញ្ចឹង...! នាងខ្ញុំវិញ តូចចិត្តនឹងព្រហ្មលិខិតណាស់ មិនគួរណាបង្កើតរូបនាងខ្ញុំមកហើយ ឱ្យមានរូបខុសខ្នាត ធាត់កន្ទ្រើខ្លីកន្ទុបដូចកន្តុំញាត់អង្ករជ្រុលអញ្ចឹងឡើយ...! អ្នកបងស្អាតយ៉ាងនេះ នាងខ្ញុំខឹងច្រណែនខ្លាំងណាស់...! នាងខ្ញុំសូមផ្សងគ្រប់ៗជាតិ សុំប្រាថ្នាឱ្យមានរូបសម្រស់ស្រស់ស្អាតដូចអ្នកបង...! បើស្អាតបវរមែននោះ នាងខ្ញុំសប្បាយចិត្តណាស់នឹងដើររើសប្តី រើសរកតែកម្លោះណាមានមាឌមាំ ស្វាក្រាស់ ខ្ពស់សង្ហា ហើយឡូយហ៊ឺហារ...! បើជួបកម្លោះស្វិតក្រទាំង ស្តមកំព្រឹងដូចប្រចៀវចង់គ្រឿង សម្បុរខ្មៅអ៊ួញ ជុំក្លិនម្ទិះៗ ស្រែៗ គម្រឹងគម្រាំងដូចគល់ត្នោត ហើយក្រតាករខាក អីយ៉ូយ សូមថយបីតឹឡូ...! នៃៗ មើលមុខនាងខ្ញុំចុះចាស់ នាងខ្ញុំមិនដាច់ដាប ស្រវាយកធ្វើជាប្តីទេ ខ្លាចខូចរាង ខូចចំរ៉ើសជិននាងខ្ញុំណាស់...! ប៉ុន្តែ បើប៉ះកម្លោះត្រគាកបាន សង្ហាដូចទេវបុត្រជិះឡានគ្រប់ម៉ាក ខោអាវមិនបាក់ភ្លីដូរគ្រប់ម៉ូត លុយចាយតឹបៗ ឈឹបៗឱ្យហូរដូច

ទឹក ហើយមានរីឡាធំចង្រ្កាង១ អូហូ សូមអញ្ជើញចូលម៉ោចាំស...! នាងខ្ញុំនេះមិនសូញសាញទេ បើពិតជាគូស្នេហ៍រុងរឿងពីអតីតជាតិមែននោះ...! នាងខ្ញុំនឹងដាក់ទុនស្នេហ៍អ្នកប្រុសបងពុំខានទេ...! " ។ រអ៊ូរទាំយ៉ាងកន្ទក់កន្ទេញតែម្នាក់ឯង ភ្លេចគិតពីរូបសម្រស់ខ្លួនស្រាប់តែនាងកន្ទាត់កខ្ចីក៏ភ្ញោចខ្លួនភ្ញាក់ ហើយឧទាន.,. " មើល៍តែអាចៅចាក់ស្មុគ...! ស្មានតែខ្លួនឯងបវរកញ្ញា...! តាមពិតខ្លួនឯងកន្ត្រើរញូកន្តុញ ដើរទូលជ្រក់ផ្លែឈើលក់សោះ...! " ។ នាងចាក់ស្មុគលបសើចឃឹក១ រួចដើរសសៀរមមៀរចេញទៅទាំងក្រអឹមក្រអៀម ដូចខកបំណងក្នុងជីវិតជាខ្លាំង ។

នៅពេលនាងកន្ទាត់កទាល់ដើរចេញទៅ ក៏បុកនឹងម៉ូតូតាចាស់ម្នាក់ ដែលបើកត្រឹក១មកឈប់ ធ្វើឱ្យតាចាស់ភ្ញាក់ព្រើត រួចបើកភ្នែកធំគ្រលួងសម្លក់មកនាងធាត់កន្តុញហើយប្រឹងឈរដកកសម្លឹងមកនាងក្រមុំរូបស្រស់ ។ តាចាស់ដោះមួកមកបក់រំហើយខ្លួនបណ្តើរ ខំញញឹមស្ញេញទាំងថ្ពាល់ផតក្រហូងបណ្តើរ ហើយលើកដៃស្ទាបសក់ស្កូវសព្រោងខ្លួនឯង ដោយលបខ្មាសខ្លាំក្នុងចិត្ត... " ចៅអូន ពិតជាស្អាតអស្ចារ្យណាស់ចៅអូន...! បងតាមិនមែនចាស់គ្លោតទេ គឺបងតាជាចាស់ដូង ចាស់រឹង មិនចាញ់ចៅស្ទាវ១ទេចៅអូន...! បើចៅអូន មានភ័ព្វវាសនាបានបងតាថ្នាក់ថ្នមមែននោះ បងតាមិនឱ្យចៅអូនធ្វើអ្វីទាំងអស់...! បាយមិនឱ្យដាំ ឧសមិនឱ្យពុស ទឹកមិនឱ្យរែក ចៅអូនខំបន្ទុំខ្លួនអប់សម្រស់ ថែក្លិន ថែសាច់ទន់រលោងរបស់ចៅអូនចុះ បងតានឹងពុះពារបម្រើចៅអូនទាំងអស់...! បងតាខំប៉ូវផ្លែឈើ ប៉ូវពងមាន់ ប៉ូវស្រាល្អ១ឱ្យមានកម្លាំងខ្លាំងក្លា ដើម្បីបម្រើចៅអូនមិនឱ្យខុសបំណងឡើយ...! សូម្បីតែសត្វស្រមោចវារកាត់លើសាច់ចៅអូន បងតានឹងចាប់ញេចកម្ទេចចោលភ្លាមណាចៅអូន...! រចៅអូន ពិតជាស្រីស្រស់ស្រីង្គារ ល្អបញ្ចង់ គួរឱ្យចង់រួមតម្រេកណាស់ចៅអូន...! មើលមុខបងតាម៉ោចៅអូន មុខបងតាមានមន្តស្នេហ៍ស្រស់សង្ហាខ្លាំងសម្បើមណាស់ចៅអូន...! " ។ កំពុងខ្សឹបខ្សាវតែម្នាក់ឯង តាក៏ព្រើលក៏លូកដៃទាញកញ្ចក់តូចចេញពីហោប៉ៅខោមកឆ្លុះមើលមុខខ្លួន ស្រាប់តែភ្ញាក់ ហើយរបូតសម្តី... " ចុំម...! កណ្តុំឆែប...! អារបល់យក៏...! យើងខំប៉ូវផ្លែឈើណាស់ដែរ មើលមុខយើង



យូរ១ទៅនៅតែដូចស្វាព្រាហ្មណ៍ទៀត...! ស្វាថាមិនស្វា មុខបងតាដូចស្វាមែន...! " ។ តាស្ទាវកំហិលសើចហ៊ាស១ ក៏របូតធ្មេញដាក់ទាំងក្រាសខ្ចាតចេញពីមាត់ជ្រុះទៅប្រឡាក់ដីរួចក៏ខ្ទប់មាត់ឱនរើសធ្មេញធ្លាក់ ធ្វើឱ្យអ្នកលក់ដូរនៅទីនោះហ៊ោគ្រេវ ស្រែកបង្អាប់មកតាកញ្ចាស់ព្រើលលាន់ទ្រហឹង ។ តាចាស់រុញកញ្ចក់ និងធ្មេញដាក់ញាត់ចូលហោប៉ៅ ហើយពាក់មួកបាំងមុខយ៉ាងរហ័ស រួចបើកម៉ូតូចេញទៅទាំងអៀនខ្មាស ដោយលបរអ៊ូរង៉ុំរង៉ូវ... " ហ្នឹងហើយបានចំជាអាកញ្ចាស់ព្រើល ធ្វើឫកព្រោក មិនចេះមើលវ័យខ្លួន...! ឃើញស្រីក្មេងរូបស្អាតភ្លាម ចាប់ព្រើលងើលឡប់ធាតុភ្លែត...! ឱ...! អាកញ្ចាស់សក់សម្កូវយើងអើយ...! " ។

កំពុងតែស្រែកចំអកចំអន់មកតារត់ម៉ូតូឱប អ្នកលក់ទាំងអស់នោះក៏សើចសប្បាយនឹងរឿងរ៉ាវមួយថ្មីទៀត ដោយឃើញនាងម្នាក់ ស្តមកំប៉េវអារ៉េវ សក់រតេរតាយដាបស្មា មុខច្របូញ ធ្មេញច្រពើស ភ្នែកល្បៀនក្រឡោត ច្រមុះខើចកញ្ជើញ មាត់សំពែះសម្បុរស កំពុងកាន់នំបុ័ង ដេញវាយបុរសម្នាក់ធំក្រអាញ សម្បុរខ្មៅដូចក្អែកទឹក ក្បាលទំពែក ច្រមុះប៉ោងធំ មុខកើតមុនឱ្យកន្ទីសឡើងឃ្មិល មាត់ធំច្រវាប ហើយស្ត្រីនោះលើកនំបុ័ងវាយបុរសនោះបណ្តើរ ស្រែកជេរប្រមាថពាសវាលពាសកាលបណ្តើរ... " អាតាប៉ិកញ្ចាស់...! ឃើញស្រី១ស្អាតមិនបានទេ ដកកចំហមាត់តាមមើលឱ្យរហូត...! យើងទ្រាំយូរហើយ នឹងឫកអាប្តីឆ្កួតឡប់នឹងស្រីក្មេង...! យើងហ្នឹងវាមិនស្អាតអ្វី បានជាឃើញស្រីស្អាតភ្លាម ហៀរទឹកមាត់ឱ្យកក្លាក់ ភ្លេចលក់នំបុ័ងអស់រលីងអញ្ចឹង...?! អាប្តីជើងល្អ...! អាប្តីឡប់សតិ...! " ។ បុរសជាប្តី ចេះតែរត់គេចបណ្តើរ សើចហ៊ែស១ចំអែចំអន់មកនាងជាភរិយាបណ្តើរ... " បើមានភ្នែកមិនមើលស្រីស្អាត ឱ្យមើលស្រីសម្ញេញ ធ្មេញច្រពើសឯងអ្វី...?! ប្រុស១គឺតែអញ្ចឹង សូម្បីតែតាចាស់អម្បាញ់មិញ ក៏សើចទាល់តែជ្រុះធ្មេញដែរ...! យាយប៉ិឯងកុំប៉ិនចាប់កំហុសរករឿងនឹងយើងពេក...! ប្រច័ណ្ឌអីក៏ប្រច័ណ្ឌម្ល៉េះ យាយប៉ិសង្វិត...! " ។

ស្វាមីកំហូច ចេះតែស្រែកបង្អាប់មកភរិយាតាមបែបកំប្លុកកំប្លែង ដោយរត់ទៅ

ឈរលក់នំប៉ុងទាំងនៅសើចកក្អឹក ហើយនាងជាប្រពន្ធចេះតែឆ្មៀតក្រឡេចមាត់ សម្លក់មកស្រស់ស្រីរូបស្អាត ហាក់ខឹងសម្បារក្នុងចិត្ត ។ បន្ទាប់មក ក៏ឃើញបុរសលក់នំប៉ុងឱបប្រឡែងភរិយា ដោយសើចកក្អៀក ។

នាងក្រមុំមិនទាន់ស្គាល់ឈ្មោះ ខ្ទប់មាត់សើចដូចនឹងអ្នកលក់ទាំងអស់នោះដែរ កាលបើឃើញទិដ្ឋភាពគួរឱ្យអស់សំណើចបែបនេះ ។ ក្រុមអ្នកលក់ ឈរសម្លឹងមកស្រស់ស្រីរូបសោភាបានបន្តិច ក៏បំបែកគ្នាបណ្តើរៗទៅលក់ដូរបន្ត នៅតាមរថយន្តនានាទើបនឹងចូលមកចត ។

ស្រស់មាណវីរំកិលជំហានមកឈរជិតក្បាលយាន ក៏ជួបនឹងអ្នកកម្លោះម្នាក់មានមុខស្រស់ សម្បុរសដូចកូនចៅចិន ពាក់អាវយឺតឆ្នូតបង្កង់ កំពុងរំកិលខ្លួនដើរមកក្បែរ ដោយនៅលើដៃទាំងពីរមានកាន់កន្ត្រងនំផ្លែអាយ ទាំងសើចប៉ប្រិម :

- កញ្ញារ័តន៍...! អូនឃើញទេ នរណាក៏ដោយ ក៏លង់នឹងសម្រស់អូនដែរ...! បងគិតថា បើដល់អង្គរវត្តទៀតនោះ ច្បាស់ជាពួកទេសចរបរទេសទាំងនោះ នឹងឆ្កួតចិត្តពីសម្រស់អូនមិនខាន...! អូនស្អាតមែនណា កញ្ញារ័តន៍...!

**កញ្ញារ័តន៍** ក្តាប់មាត់សម្លក់មកអ្នកកម្លោះ ដោយក្តាប់ដៃគក់ស្មានរៈឱប១ :

- បងកុសល កុំមាត់រអិលប៉ប្លែចប៉ប្លុចខ្លាំងពេក..! មាត់បងឯងនេះស្តិញណាស់..!

**កុសល** កម្លោះរាងសង្ហាញាក់ចិញ្ចើម ហើយនៅតែបញ្ចេញឫកពាប៉ប្លេះប៉ប្លោះដាក់មកឆោមល្អ ដែលកំពុងឈរមួហ្មង :

- នេះជាថ្ងៃទីមួយហើយ ដែលកញ្ញារ័តន៍មាសបង ធ្វើជាមគ្គុទ្ទេសក៍ទេសចរ ហើយក៏ជាថ្ងៃទីមួយដែរ ដែលធ្វើឱ្យអ្នកនៅផ្សារស្តន់ផ្អើលឈូឆរ...! ចុះទម្រាំបើធ្វើជាមគ្គុទ្ទេសក៍ទេសចរ គ្រប់ទីតំបន់ជារៀងរាល់ថ្ងៃទៀតនោះ ពិតជាផ្អើលរឹករវរ ពីសម្រស់មគ្គុទ្ទេសក៍ក្រមុំរូបស្អាត ឈ្មោះកញ្ញារ័តន៍មិនខានទេ...! ឱ...! មគ្គុទ្ទេសក៍ទេសចរក្រមុំអើយ ម្តេចក៏ស្រស់បំព្រងបែបនេះហ្ន៎...?

កែវកញ្ញារ័តន៍ រលាស់ចង្កេះធ្វើឫកក្អិកក្អក់ :



- ពូកែប៉ប៉ាច់ប៉ប៉ោចណាស់ បងកុសល...! មើល៍នំផ្លែអាយឡើងក្រៀមក៏ពិតទៅហើយ នៅមិនព្រមញ៉ាំទៀត តែបែរជាខំប្រឹងពីរឿងមិនបានការទៅវិញ...! អូនថា ស្មារតីបងឯងកាន់តែវង្វេងវិងស៊ុងដូចគេឯងហើយ...! តិច១ បើកឡានវង្វេងធ្លាក់ស្រែណាអ្នកកម្លោះមាត់ដាច...!

អ្នកបើករថយន្តទេសចររូបឆើត ឈ្ងោកមើលនំផ្លែអាយបន្តិច ក៏ងើបមុខឡើង ហើយសើចកខឹកដដែល :

- បងមិនអាចវង្វេងបើកឡានធ្លាក់ស្រែបានឡើយ...! កុសលបង សូមធានាសុវត្ថិភាពមួយរយភាគរយ...! បើអ្នកណាមិនស្គាល់តែកុងឡានជើងថ្មី ដៃចំណានឈ្មោះកុសល ក៏ដូចមិនស្គាល់អង្គរវត្តអញ្ចឹង...!

ឆោមនវនាថញាក់ស្មាពេបមាត់ចៀប ហើយវេក្រសែភ្នែកសម្លឹងទៅរថយន្តម៉ាកទំនើបមួយដែលចតសំអែលនៅក្បែរនេះចម្ងាយប្រមាណបីម៉ែត្រ ដោយឃើញមនុស្សម្នាក់កំពុងឱនឈ្ងោកជូសជុលយានយន្តទាំងបើកគម្របក្បាលយានបះច្រងាង ដូចឈរកំបាំងខ្លួនស្ទើរមិនឱ្យឆោមល្អបានឃើញរូបរាងច្បាស់ប្រាកដ ។ នាងកញ្ញាលបឆ្ងល់ក្នុងចិត្ត..." ចម្លែកដែរ...! មនុស្សតម្លង់ ថ្ងង់ដងើចទេដឹងអេះ គេស្រែកហៅកញ្ជៀវលាន់កងរំពងផ្អើលអស់ម៉ាផ្សារស្តន់ បែរជានៅប្រឹងឈរសម្ងំធ្វើឡានយ៉ាងព្រងើយទៅវិញ...! ប្រហែលជាត្រចៀកប៉ោត ឆោតដូចអាដៃទេដឹង...? ម្យ៉ាងដែរ មនុស្សតម្លង់ខ្ជិលប្រកាន់...! " ។

នៅពេលឃើញឆោមស្រស់ភ្លឹកអារម្មណ៍ ឈរភាំងសម្លឹងទៅរថយន្តនោះ ធ្វើឱ្យកុសលងាកក្បាលសម្លឹងតាម ដោយជម្រុះសំណួរផ្ទុកការងឿងឆ្ងល់ :

- អូនសម្លឹងអីហ្នឹង...? អូនអត់ឮបងនិយាយទេអ្វី...?

ស្រស់តរុណីភ្ញាក់ខ្លួនដោយភ្ញាក់ ហើយងាកមកសើចស្រស់ដាក់តែកុងឡានកម្លោះ :

- ឮទេតើ...! សូមឱ្យចំណាប់ដូចមាត់បងថាចុះ អូនសូមអរគុណហើយ...! ប៉ុន្តែនៅតាមផ្លូវធ្វើដំណើរនោះ សូមមេត្តាកុំស្ងាបងងុយដេកឱ្យសោះ...! តិចប្រយ័ត្ន...

កុសលចាប់កន្ទោងនំមកដាក់ត្រួតគ្នានៅលើដៃម្ខាង រួចលើករាខ្ចាស់កាត់ទាំងចាប់នំផ្លែអាយញាត់ចូលមាត់ទំពាប៉ប្លោញបណ្តើរ ខំនិយាយឡូល១ស្ទើរពុំឮសម្លេងច្បាស់បណ្តើរៈ

- គេថានៅពេលបើកបរ បើដេកកុំបើក បើបើកកុំដេក...! ហើយមានពាក្យមួយឃ្លាទៀតថា បើស្រវឹងធ្លាក់ភ្នែកកុំបើកបរ បើបើកបរកុំស្រវឹងធ្លាក់ភ្នែក...! ម៉េចយល់ឬនៅស្រីស្អាត...?

- ពូកែទ្រឹស្តីណាស់ តែកុងដើងថ្មី...! ប៉ុន្តែ បើបាននំផ្លែអាយវិញ ភ្លេចគេឯងអស់រលីង...! ហ្នឹងបានចំជាកំពូលមនុស្សចិត្តបានមែនទែន...! នៅលើលោកនេះប្រហែលជាមានតែម្នាក់ទេមើល៍ទៅ...!

កែវមាណវីនិយាយទាំងសើចកក្បេក នាំឱ្យនរៈញាក់ចង្កេះធ្វើឫកភ្ញាក់ ដោយសើចគ្រហាញចេញសាច់នំល្បៀនស្ប៉ឹម ហើយហុចនំមួយកន្ទោងមកឱ្យនាងក្រមុំ ទាំងខំទំពានំប៉ផ្ទាច់ មិនដាច់ពីមាត់ ៖

- អូ១ ភ្លេចគិត១...! បងស្មានថា ស្រីស្អាតមិនត្រូវការទេ ព្រោះខ្លាចខូចសម្រស់...! តែមានអី ចេះឃ្លានដែរទេតើ...! អញ្ជើញ១ តាមត្រូវការចុះ...!

នាងក្រមុំទទួលកន្ទោងនំមកកាន់ ដោយគ្រវីក្បាលហាក់ហួសចិត្ត ៖

- ចំណាប់ខាងក្លែមសម្តី មិនចេះរួយមាត់សោះ បងកុសលឯងនេះ...! ឱ...! នាងជំទើតតូចឯមួយណាទៅ មានវាសនាបានកម្លោះមាត់ដាច ឈ្មោះកុសលធ្វើជាប្តីទៅហ្ន៎...! បើមាត់រអិលដូចគេលាបខ្លាញ់អញ្ចឹង ច្បាស់ជានាងជំទើតតូចឯង ដេកប្រេះដើមទ្រូងស្លាប់មិនខានទេ...! ឱ ប្រុសកំហិល មាត់កំហូច...!

តែកុងឡានមុខស្រស់សើចឃឹក ក៏ធ្លាក់នំផ្លែអាយជ្រុះចេញពីមាត់ ហើយបើកភ្នែកមូលក្រឡង់ ៖

- គ្មាននាងជំទើតតូចឯណាទេ កញ្ញារ័តន៍...! គឺអូនហ្នឹងឯង ជាកំពូលភរិយារបស់បងនៅថ្ងៃអនាគត...! បងខំផ្តាប់នំទាំងកន្ទោងប៉ុណ្ណឹងហើយ នៅតែមិនទាន់ស្គាល់ចិត្តទៀត...! កុសលកញ្ញារ័តន៍ ឈ្មោះយើងទាំងពីរពិតជាសមគ្នាណាស់ ណាព្រះម្ចាស់



ថ្លៃ...! ប្តីជាអ្នកបើកឡាន ប្រពន្ធជាអ្នកនាំភ្ញៀវ...! អីយ៉ូយ លុយមូល ហូរចូលឈីប១តែម្តងហើយ...!

ស្រស់ស្រីក្តាប់មាត់សម្ងក់ហាក់គ្រឹតក្តាញ់ ហើយលើកកន្ទោងនំដាក់ជន្លមកក្បែរវង្វេះមាត់អ្នកកម្លោះ ដោយស្រដីផ្ញៀផ្ងាន់ទៅវិញ ៖

- កុំមាត់រឡាញខ្លាំងពេក អូនគ្មានវាសនាជាមួយទេ...! តិចញ៉ុកនំផ្លែអាយចូលពេញមាត់ឥឡូវ...! កំហិលណាស់មាត់ហ្នឹង...! នែ៎១ អញ្ជើញដើរមើលកង់ឡានបន្តិចទៅមើល៍ យើងជិតចេញទៅសៀមរាបឥឡូវហ្នឹងហើយ...! កុំពូកែខាងលែបខាយសម្តីពេកកម្លោះភ្នែកលលាម...!

ឮប្រយោគស្រស់នារីភ្លាម កុសលធ្វើជាលើកដៃគំនាប់ ដោយទាញជើងឈរត្រង់ភ្លឹង ហើយធ្វើជាមិចភ្នែកព្រិច១ ៖

- ទទួលបញ្ជា រាជិនីមគ្គុទ្ទេសក៍...! ទូលព្រះបង្គំ ស្តាប់តាមព្រះរាជបញ្ជាជានិច្ច...! ព្រះរាជិនីចង់ឱ្យទូលព្រះបង្គំធ្វើអ្វី ក៏ព្រមដែរទាន...! កុំថាឡើយឱ្យចូលរន្ធក្តាមក៏ព្រមទៀតណា...!

- យ៉ាប់មែន បងកុសលនេះ...!

កញ្ញារ័តន៍បែរមុខចេញទាំងសើចឃឹក១ ហាក់មិនប្រកាន់នឹងចរិតលលីមលលាមនៃតៃកុងឡានមុខស្រស់ ធ្វើឱ្យកុសលដើរតយង់យចេញទៅ ហើយដើរឱនប៉ផ្ចិតប៉ផ្ចូងត្រួតពិនិត្យសំបកកង់យានយន្ត ទើបរ័តន៍នារីបង្វែរខ្លួនចេះតែដើរថយក្រោយរំកិលជំហានយឺត១ មកឈរអែបនឹងក្បាលរថយន្តម៉ាកទំនើប ដែលមានមនុស្សកំពុងជូសជុលនោះដោយពន្លឺចក្ខុចេះតែតាមសម្លឹងមកក្រុមអ្នកទេសចរ ដែលកំពុងបណ្តើរគ្នាត្រសងឡើងទៅលើរថយន្ត និងខំឱនតាមគន់រំពៃកុសលកំពុងដើរពិនិត្យសំបកកង់យាន រួចនាងបម្រុងលើកនំផ្លែអាយបង់ចូលមាត់ ស្រាប់តែឮស្នូរគ្រឹបលាន់ខ្ទរយ៉ាងខ្លាំងនៃការបិទគម្របក្បាលយាន ធ្វើឱ្យនាងក្រមុំភ្ញាក់ខ្លួនព្រើត ក៏ជ្រុះគ្រាប់នំអស់រលីងពីកន្ទោង ហើយខំបង្វិលខ្លួនយ៉ាងលឿនងាកទៅ ក៏បុកផ្អឹបនឹងខ្លួនប្រាណអ្នកកម្លោះកំពុងឈរជូសជុលយាន ដែលទើប

តែខំស្រែករអ៊ូរទាំ :

- ថ្មីតែពណិទេលោកអើយលោក បើកមិនបានប៉ុន្មានផងក៏រលត់ស្ងាត់ឈឹង...! ចំជាមហាយ៉ាប់មែនអាឡានថ្មីយើងចាស់គេ..! ធ្វើម៉ាព្រឹកទៅហើយនៅមិនឆេះទៀតវ៉ើយ..!

លុះស្រែករអ៊ូបណ្ដើរ ខំងើបឈរបង្វែរខ្លួនលឿនជ្រុលបណ្ដើរ ហើយបែរមកជល់ផ្ទឹបនឹងប្រាណនាងក្រមុំឈមមុខគ្នាយ៉ាងរហ័សអញ្ចឹង អ្នកកម្លោះមុខមានមន្តស្នេហ៍សម្បុរខ្មៅស្រអែមស្រស់ ស្អាធំមាំ រាងស្រោងខ្ពស់ស្រឡះ ក៏ភ្ញាក់ស្រឡាំងកាំង ។ ឯឆោមស្រស់ ក៏ភ្ញាក់ស្រឡាំងកាំងដែរ ដោយយកដើមទ្រូងបុកផ្ទឹបមកដើមទ្រូងអ្នកកម្លោះស្ទើរនឹងរកកលដួលដាច់ផ្ងារទៅក្រោយទាំងជំហរទៅហើយ ក៏ត្រូវនរៈមុខស្រស់សម្បុរស្នេហ៍ស្រវាកៀកចង្កេះយ៉ាងរហ័ស រួចទាញត្រកងដងខ្លួនស្រស់ស្រីឱ្យទប់ជំហរតាមសម្រួល រួចបង្អើរសម្ដីទ្រគោះបោះបោកមកពញ្ញាក់ស្មារតីឆោមឆវី ទាំងគ្មានញញើតភ្នាម :

- ខ្វាក់ភ្នែកទេអ្វី បានជាមិនឃើញគេកំពុងធ្វើឡានអ៊ំា...? ពភ្លីពភ្លើអញ្ចឹង ក៏ប្រឹងចំណាប់មកឈរក្បែរឡានគេកើតដែរ...! គួរឱ្យជិនឫក ចង់ក្អួតខ្លាំងណាស់...!

នៅពេលឃើញប្រតិកម្មអ្នកទាំងពីរប៉ះទង្គិចគ្នា ដោយដើមទ្រូងទល់នឹងដើមទ្រូងយ៉ាងលឿនត្របាញ់បែបនេះ អ្នកលក់ដូរ អ្នកទេសចរ និងអ្នកធ្វើដំណើរនៅទីជិតនោះ ក៏ភ្ញាក់ផ្អើល ហើយចោមសម្លឹងមកគ្រប់ៗគ្នា ទាំងទះដៃបន្ទរសើចក្អាកក្អាយ ។ កុសលវិញបែរជាធ្វើមុខមាំដោយឈរតន្ត្រំជើង ខាំមាត់សង្រ្កិតធ្មេញ ក្ដាប់ដៃឡើងញ័រទទ្រើក ហើយបើកភ្នែកធំក្រឡោតសម្លក់មកអ្នកកម្លោះរូបសង្ហានោះ ស្ទើរចង់លេបត្របាក់ទាំងរស់ ។

ចំណែកឆោមនរនាថវិញ ដោយភ្ញាក់ឡេះឡះធ្វើអ្វីមិនកើត ណាមួយក្ដៅក្រហល់ក្រហាយនឹងសម្ដីគំរោះគំរើយរបស់អ្នកកម្លោះផង ណាមួយខ្មាសគេឡើងមុខក្រហមងាំងផង ក៏លើកកន្ត្រោងនំផ្លែអាយដែលនៅកាន់ជាប់ក្នុងដៃ មកប៉ាតញាត់មាត់នរៈមាត់ឆៅយ៉ាងលឿន រួចរើកព្រោលច្រានទ្រូងចេញ ទើបលើកដៃចង្អុលមុខ ខមសម្លក់ :

- នែ៎តាប៉ិមុខជម្ភ...! តាប៉ិមាត់ស្អុយ...! មាត់តាប៉ិឯង អីក៏ស្អុយស្អោកគ្រោកខ្លាំងម្ល៉េះ...! ហាមាត់សំអុយភ្លែត ប្រមាថកាតទានគេគ្មានញញើតភ្នាម...! មាត់សំអុយ



ហ្នឹង សមតែទះឱ្យបែកមាត់ហូរឈាមរ៉ាវទេ ទើបស្គាល់ពាក្យសុជីវធម៌ចំពោះនារីភេទ...! យីតាប៉ិមាត់ប្រហុក តាប៉ិមាត់កង្កែបនេះ...!

នរៈមុខស្រស់សម្រស់បាន ខំព្រួសខ្ជាក់កន្ត្រោងស្ពឹកចេកចេញពីមាត់បណ្ដើរ ខំលើកដៃមកជូតសម្អាតមុខបណ្ដើរ ធ្វើឱ្យម្រាមដៃដែលប្រឡាក់ប្រេងម៉ាស៊ីននោះ ដូចបានមកប៉ាតប្រតាកខ្មៅញញួពេញផ្ទៃមុខ ហើយក៏ត្រញ៉ែងខ្លួនឈរជំទែងស្រែកសង្ឃកមកកាន់នាងក្រមុំ ដោយមើលទៅឃើញមុខដូចតួត្លុកល្ខោនបាសាក់ :

- កុំច្រែតៗមើលតែចង្រិតដែកពេក យាយប៉ិមាត់ចង្រិត យាយប៉ិមាត់ហ៊ីង...! តាប៉ិមាត់កង្កែបខ្ញុំ ចង់ជ្រលក់មាត់ជាមួយយាយប៉ិមាត់ហ៊ីងឯងណាស់អ្វី...? ឆ្អើយ ឆ្អើមណាស់...! មើលមុខមើលមាត់ស្រស់ស្អាតគ្រាន់បើដែរ បែរជាស្រែកវ៉ែបៗដូចមាត់ហ៊ីងយំទារទឹកភ្លៀងទៅវិញ...! អូ... ប្រហែលជាហ៊ីងក្រមុំ យំចង់បានប្ដីទេដឹង...? នែ៎ៗ តាប៉ិខ្ញុំនេះនៅកម្លោះចែស ទំនេរស្អាត...! បើចង់បានប្ដីណាស់ តាប៉ិខ្ញុំនេះអាចកាត់បេះដូងប្រគេនជូនទ្រូងយាយប៉ិបាន...! មិនបាច់ទៅណានាំឱ្យតែឆ្ងាយទេ យាយប៉ិមាត់ឆ្អើម...!

កញ្ញារ័តន៍មុខក្រហមងៅ ដូចគេយកអណ្ដាតភ្លើងទៅរោល ហើយក្ដាប់មាត់ស្រែកគំហកមកវិញ ហាក់ភ្លេចភាពអៀនខ្មាសដែលខ្លួនជាស្ត្រីភេទ ក្នុងចំណោមមនុស្សឈរកកកុញកំពុងចោមរោមសម្លឹង :

- ផេះ...! ខ្មៅរលើបឡើងរលោងដូចផ្លែព្រីងទុំអញ្ចឹង ក៏ប្រឹងអួតដែរ...! សូម្បីតែក្លិនក៏ធុំផ្ដូរ គួរឱ្យចង់ក្អួត...! កុំៗចង់កាត់បេះដូងប្រគេននោះ ទៅមិនរួចទេកម្លោះមុខស្ពឹក កម្លោះថ្លើមយោល...!

កម្លោះរូបសង្ហាញញួធ្មេញ ខំតវ៉ាយ៉ាងប៉ប៉ែះមកទៀត :

- យី... យាយប៉ិនេះ សម្ដីឡឺតៗមិនអន់ទេហ្ន៎...! ហៅឯងសុទ្ធតែតាប៉ិមុខជម្ភ តាប៉ិមាត់ប្រហុក...! ដល់ឥឡូវ ហៅឯងកម្លោះមុខស្ពឹក កម្លោះថ្លើមយោល...! ចុះថ្លើមយាយប៉ិឯង អត់យោលទេអ្វី បានជាកាចឆ្នាសឆ្អើមអញ្ចឹងអ៊ំា យាយប៉ិម្ទេសទុំ...?

ឆោមពិសីបម្រុងហាមាត់ជម្លោះតទៅទៀត ក៏ឃើញកុសលដើរញែកគេឯងចូល

មក ហើយខាំមាត់សម្លក់សម្លឹងមកនរៈរូបសង្ហា រួចសើចពេបមាត់ចំអក ៖

- បានហើយៗ អូនឯងទៅជ្រលក់មាត់នាំឱ្យតែខ្មាសគេធ្វើអី...! សម្លៀកបំពាក់ឱ្យខ្ទង់គ្មានបាក់ភ្លី មិនស៊ីនឹងចរិតបន្តិចណាសោះ...! មនុស្សប្រុសស្អី ចេះឈរជម្លោះជាមួយមនុស្សស្រីទៅកើត...! តស់យើងទៅវិញ...!

ឮសម្ដីកុសលភ្លាម អ្នកកម្លោះចិត្តស្អុយក៏ញោចខ្លួនបម្រុងស្ទុះមករក ក៏ត្រូវទច់ជំហានរួចដកថយ ដោយឃើញស្រស់ទងវង្សរុញខ្លួនផ្ដើនទៅវិញ ទាំងពេបមាត់គ្មានក្ដាញ់ ៖

- មើល៍តែឯងម្ចាស់ផែនដី...! សម្ដីអសុរោះមើល៍តែពូកពាល...! កម្លោះស្អីមាត់ដាចយ៉ាងនេះ មិនដែលឃើញទេ...! កម្លោះថ្លើមយោល...! កម្លោះច្រៃចាប់...!

ថាហើយ កែវកញ្ចាវ៉ែតន៍ល្បឿនអណ្ដាតស្ទីលចំអកជំទយ ហើយដើរត្រសងជាមួយកុសលមកកាន់រថយន្ត ធ្វើឱ្យអ្នកកម្លោះចិត្តឆ្នើមព្រលយសម្ដីបង្ហើរតាមក្រោយ ៖

- ផែនដីវិល គង់តែជួបគ្នាទេ យាយប៉ុម្ពេសទុំ...!

ប៉ុន្តែ នៅពេលអ្នកទាំងពីរកំពុងឈរឈ្លោះប្រកែកគ្នា អ្នកដែលបានមកចោមព័ទ្ធមើល៍វេទិកាជម្លោះនេះ ចេះតែនាំគ្នាទះដៃសើចហ៊ោ ដោយមិនគួរណាឃើញកម្លោះរូបស្អាត ក្រមុំរូបស្រស់ បែរជាឈរជម្លោះគ្នាឡើងតឹងសរសៃកអញ្ចឹងឡើយ ។

នៅពេលឃើញមគ្គុទ្ទេសក៏ទេសចរក្រមុំឡើងលើរថយន្តផុតទៅ ទើបពួកគេផ្ទុះសំណើចទះដៃស្រែកហ៊ោគ្រេវៗ ចំអកបង្អាប់នឹងមុខមាត់អ្នកកម្លោះមាត់ឆៅម្ដងវិញ ។ នរៈសើចហ៊ែសៗលែងសម ក៏ដើរទ្រូបៗទៅឆ្ពុះកញ្ចក់យាន ក៏ភ្ញាក់បើកភ្នែកធំ ដោយឧទានតិចៗ ៖

- អីយ៉ាស់...! មើល៍មុខដូចមុខស្វាព្រាហ្មណ៍អញ្ចឹង ចេះប្រឹងឈរជម្លោះកើតដែរ...! ថ្ងៃនេះ ចំជារង្សីធ្លាក់ចុះយ៉ាងត្រដែតមែនវ៉ើយ...! ឈ្លោះមិនប៉ះចំអ្នកណា បែរជាប៉ះចំស្រីស្អាត សាច់សទន់រលោងឱ្យកំភើៗទៅវិញ...! អារំបល់កាច់ថាវរៈ មហាមាត់ឆៅយើងអើយ...! ថាវរៈអើយថាវរៈ...!

**ថាវរៈ** សើចស្ញេញចេញធ្មេញស្វាញដាក់កញ្ចក់ឆ្លុះមុខ ធ្វើឱ្យមនុស្សម្នាចោមរោម



មើលការឈ្លោះគ្នា នាំគ្នាខ្ទប់មាត់សើច ហើយដើរបំបែកគ្នាចេញអស់ទៅ ទើបនរៈទាញកូនកន្សែងចេញពីហោប៉ៅខោមកជូតសម្អិតសម្អាតលើផ្ទៃមុខ រួចចេះតែដៀងកន្ទុយភ្នែកសម្លឹងទៅរថយន្តទេសចរនោះដែលកំពុងបើកចេញទៅសន្សឹមៗ រំកិលបត់ទៅច្រកផ្លូវជាតិលេខ៦ ។

ខណៈនោះ ទូរស័ព្ទដៃក៏បានរោទិ៍បន្លឺសម្លេងឡើង ទើបថាវរៈលូកទាញទូរស័ព្ទពីក្នុងហោប៉ៅខោ មកឈរឱនត្រុនៗនិយាយទូរស័ព្ទទាំងឈ្ងោកមុខឆ្លុះកញ្ចក់យាន និងដៃម្ខាងទៀតនៅកាន់កូនកន្សែងប្រឹងជូតសម្អាតស្នាមប្រឡាក់ ៖

- អាឡូអាសម្លាញ់...! ឯងម៉ោដល់ណាហើយហ្នឹង...? សូមឱ្យលឿនបន្តិចម៉ោយើងប្រញាប់ទៅប្រជុំនៅម៉ោងពីររសៀលនេះផង...! បើខកខាន ច្បាស់ជាអាសន្នជាន់កហើយវ៉ើយ...!

លិខិត ជាមិត្តសម្លាញ់របស់ថាវរៈ ហើយលិខិតក៏ជាវេជ្ជបណ្ឌិតរូបសង្ហាមួយរូបដែរ ។ លិខិតមានគ្លីនិកមួយទើបនឹងបើកទទួលព្យាបាលអ្នកជម្ងឺ ដោយដាក់ឈ្មោះគ្លីនិកនោះថា គ្លីនិកលិខិតពហុព្យាបាល ។ ចុះថាវរៈវិញ តើគេបំពេញការងារក្នុងតួនាទីជាអ្វី ហើយកម្រិតការសិក្សាជាអ្វីដែរ...? ។

លិខិតបញ្ឈប់រថយន្តបណ្ដើរ និយាយទូរស័ព្ទមកកាន់ថាវរៈបណ្ដើរ ដោយមានជាងរថយន្តម្នាក់អង្គុយទន្ទឹម ទាំងធ្វើមុខស្រស់ប៉ប្រិម ៖

- យើងមកដល់ផ្សារផ្កាវហើយ...! បើឯងប្រញាប់ រកឡានតាក់ស៊ី ឬឡានឈ្នួលណាក៏បាន ឱ្យតែគេទៅសៀមរាប ជិះទៅមុនយើងចុះ...! យ៉ាងម៉េចៗ ចាំយើងទាក់ទងគ្នាតាមក្រោយទៀត...!

ថាវរៈគ្រវែងកូនកន្សែងចោល ហើយឈរនិយាយតាមសម្រួល ទាំងពន្លឺភ្នែកមើលទៅរថយន្តទេសចរ កំពុងរំកិលទៅមុខយឺតៗ ៖

- ខ្មោចយក៏ស្អី...?! ចុះឡានយើង បានអ្នកណាគេមើល៍ទៅ...? បើទម្រាំឯងម៉ោដល់នោះ ច្បាស់ជាបាត់ស្រមោលពុំខាន...!

លិខិតគ្រវីក្បាល ហើយសើចពព្រាយ :

- ឯងនេះ សាំត្រប៉ៃណាស់...! ក្រែងបងជីដូនមួយយើង កំពុងឈរលក់នំប៉័ងអ្វីម៉េចក៏ឯងមិនទៅផ្ញើឡានឱ្យគាត់ជួយមើលទៅ...? យើងមិនដឹងទេ បើឯងដំអក់ពេលតិចខានលែងបានប្រជុំណាថាវរ:...!

ថាវរ:លើកជើងធាក់សំបកកង់យាន ដោយរអ៊ូរទាំ :

- អញ្ចឹងក៏បាន...! វើ្យ ធុញទ្រាន់ណាស់...!

លុះចុចបិទទូរស័ព្ទរួច ទើបអ្នកកម្លោះញាត់ទូរស័ព្ទចូលហោប៉ៅខោ ហើយដើរបាត់រញ៉ាត់តម្រង់ទៅរកបុរសធំក្រអាញ ក្បាលទំពែក និងស្ត្រីសំគមសង្វិត មុខច្របូញច្របញច្រពើស ដែលនៅពេលមុននេះបន្តិច បានកាន់នំប៉័ងដេញវាយតប៉ត្នានោះ ។ ថាវរ:ឈរជជែកជាមួយស្វាមីភរិយានោះ ដោយនាំគ្នាសម្លឹងមករថយន្តដែលជូសជុលមិនបាន ហើយក៏ឃើញនរ:ដើររលះរលាំងមកបើកទ្វារយាន រួចទាញកាបូបស្ពាយ និងថង់ផ្ទុកសត្វអាពីងដែលនៅរស់រវើកវារឱ្យរវាមពេញក្នុងថង់ ។

អ្នកកម្លោះមុខស្រស់ឈរមើលនាយអាយ ហាក់កំពុងស្វែងរកយានជំនិះ ដើម្បីស្រូតដំណើរទៅខេត្រសៀមរាប ។ ប៉ុន្តែមិនមានរថយន្តឈ្នួល ឬរថយន្តណាមួយបរកាត់សោះ ដោយឃើញតែរថយន្តទេសចរកំពុងបរទៅមុខសន្សឹមៗ ហើយរូបគេប្រញាប់ផងទើបនរ:លើកកាបូបមកស្ពាយ ទាំងដៃម្ខាងនៅកាន់ថង់អាពីង រួចខំរត់អន្ទ្រាកៗឡើងហួរញើសរហាម តម្រង់ទៅរករថយន្តទេសចរដែលមានស្រស់ស្រីកញ្ញារ័តន៍ធ្វើជាមគ្គុទ្ទេសក៍ទេសចរ និងកុសលជាអ្នកបើកបរ ។

អ្នកទេសចរទាំងប្រុសស្រី ក្មេងចាស់ទាំងអស់ ចេះតែលបខ្ចប់មាត់សើច នៅពេលឃើញស្រស់នារីឈរសម្លក់មើលទៅធ្លាថ្នល់ខាងក្រោយ ស្របពេលនឹងសម្តីកុសលចំអែចំអន់មកនាងក្រមុំ :

- ហ្នំ កញ្ញារ័តន៍...! អ្នកកម្លោះថ្លើមយោលនោះ ប្រឹងរត់តាមឡានយើងឡើងដាបញើសទៅហើយ យាយបុំម្ទេសទុំឯងគិតយ៉ាងម៉េចដែរ...?



- នែកម្លោះផ្លែអាយ មាត់នៅឱ្យស្ងៀមបន្តិចទៅមើល៍...! ចង់រត់ទាល់តែជ្រុះថ្លើមដល់ដី ក៏មិនឱ្យជិះជាមួយដែរ កម្លោះមាត់ឆៅហ្នឹងនោះ...! មនុស្សអស់ក្លាក់អស់កែហ្នឹង ឱ្យជិះនាំតែធ្ងន់ឡានទេ...! តែមិនស្រួលឈ្លោះគ្នាបែកមេក្រមី ផ្អើលពេញឡានផងមិនដឹង...!

ពួសម្តីស្រស់ស្រីរូបស្អាតពោលយ៉ាងដូច្នេះ កុសលសើចឃឹកៗ :

- អ្នកណាមិនស្គាល់មាត់យាយបុំម្ទេសទុំស្មោះ..! ឆ្នាសហើយចិត្តដាច់ណាស់ហ្នំ..!

- បានសម្តីណាស់ កម្លោះផ្លែអាយនេះ...!

នៅពេលនេះ អ្នកទេសចរកាន់តែនាំគ្នាសើច ហើយនាំគ្នាងាកមើលទៅដងផ្លូវខាងក្រោយ ក៏ឃើញថាវរ:រត់តាមយានយ៉ាងប្រកិតទាំងហាត់គឃ្លូវ ទើបអ៊ំស្រីម្នាក់បង្អើលសម្តីមកកាន់រ័តន៍នារី :

- ឈប់ឡានឱ្យក្មួយប្រុសជិះផងទៅ...! មើល៍នំ ប្រឹងរត់តាមឡានឡើងហាត់ដង្ហក់ទៅហើយៗប្រហែលជាមានការប្រញាប់ផងមីនាង...! កុំគិតសាន់វ៉ាន់វែងឆ្ងាយធ្វើអីអាណិតក្មួយប្រុសខ្លះទៅ...!

អ៊ំប្រុសម្នាក់ទៀត ក៏ខំអង្វរទទូចទទែមកយ៉ាងរហ័សដែរ :

- ត្រូវហើយក្មួយស្រី...! ជនជាតិខ្មែរដូចគ្នាទេ ជួយយកអាសាគ្នា ឱ្យគ្នាសុំដោយសារផងទៅ...! បើគ្មានកៅអីអង្គុយទេ ឱ្យគ្នាឈរក៏បាន...! ប្រហែលជាក្មួយប្រុសម្នាក់ហ្នឹង មានធុរ:នៅឯនាយនោះហើយ...!

បងស្រីម្នាក់ទៀតកំពុងបំបៅដោះកូន ក៏ប្រឹងជួយលួងលោម :

- ទៅចាប់ទោសអូសដំណើរធ្វើអីប្អូន មនុស្សប្រុសណាក៏ខិល ក៏ខូច ក៏មាត់ដាច ភ្លេកលលាម ឬកច្រឡឺម ដូចតែគ្នាដែរ...! មើល៍អាល្អិតកូនខ្ញុំនេះ វាធំប៉ុណ្ណឹងទៅហើយ វាក៏នៅតែទាញដោះបៅទៀត...! គេថាមនុស្សប្រុស បៅរហូតទាល់តែចូលក្តារមឈូស ទើបឈប់ទារបៅ ឈប់ច្រឡឺម ឈប់ខិលណាប្អូន...! ឱ្យគ្នាជិះផងទៅ កុំទៅប្រកាន់អីប្អូនអើយ...! ជួយគ្នាយកតែបុណ្យទៅ...!

អ្នកទេសចរនាំគ្នាផ្ទុះសំណើចឡើងរំពងពេញរថយន្ត ចំពោះពាក្យសម្ដីបងស្រីរូបនេះ ធ្វើឱ្យកុសលបានចិត្ត ពេបមាត់ ញាក់មុខដាក់ស្រស់ស្រី :

- ម៉េចព្រមទេកញ្ញារ័តន៍...? បងគិតថា ពេលនេះបងមានដៃគូ ដើងឆើតមកតាមប្រជែងតំណែងបងហើយ...! ឱ... កម្លោះថ្មើមយោលអ្ហើយ ម៉េចក៏ដាច់ដាបតាមហិតក្លិនស្រីស្អាតមកដល់លើឡានទៀតហ្ន៎...! នេះប្រហែលជាមិនអស់ចិត្ត ក្នុងរឿងជម្លោះទេដឹង...!

ឆោមស្រស់លើកដៃទះស្មាកុសលមួយដៃម៉ាំង ទើបសម្លក់ :

- ឱ្យកម្លោះច្រែះចាប់ មាត់ប្រហុកហ្នឹង រត់តាមហិតផ្សែងឡានមួយចម្អែតសិនចុះ សីមឱ្យជិះ...! ឃើញមុខភ្លាម ប្រហែលជាខ្ញុំលេបបាយលែងចូលហើយមើល៍ទៅ...! ជ្រេញអើយមហាជ្រេញ...!

មិនថាឡើយកុសល សូម្បីអ្នកទេសចរក៏សើចក្អឹកនឹងសម្ដីឆោមល្អដែរ ហើយកុសលចេះតែបន្ថយល្បឿនរថយន្តសន្សឹម១ បម្រុងបញ្ឈប់ ។ ឯថាវរៈស្មានថាយានយន្តឈប់ចតឱ្យគេបានជិះ ក៏ប្រឹងរត់យ៉ាងត្របាញ់កែងតម្រង់មកទាំងក្ដីអំណរ ។

ប៉ុន្តែ នៅពេលអ្នកកម្លោះរត់មកដល់ក្បៀក កញ្ញារ័តន៍ក៏ស្រែកវ៉ាសដាក់កុសលយ៉ាងរហ័ស :

- អូនអត់ទាន់ឱ្យឈប់ឡានទេ...! បើកឱ្យលឿនទៅមុខបន្តិចទៅមើល៍ អូនចង់ឃើញមុខកម្លោះថ្មើមយោលហ្នឹង នៅពេលហត់ធ្វើមាត់ស្មេញយ៉ាងណាបងកុសល...!

តែកុងឡានកំហិលក៏សើចស្ញាញ ហើយប្ដូរលេខបង្កើនល្បឿនយានឱ្យស្ទុះទៅមុខយ៉ាងលឿន ធ្វើឱ្យថាវរៈខកបំណង ក៏ឈរធ្វើមុខអើសមែសទាំងហេវហត់ទន់ជើង រួចក៏ទម្លាក់គូថអង្គុយចុះ ដោយតាមសម្លឹងរថយន្តហាក់អស់សង្ឃឹមជាខ្លាំង ។

នៅពេលកំពុងអង្គុយឈ្ងោកមុខសម្លឹងថង់អាពីង ហើយខំរលាក់កាបូបស្ពាយបម្រុងដោះចេញពីស្មា ទាំងនៅហូរញើសគយ្សៀវដាមពេញផ្ទៃមុខ ថាវរៈក៏ងាកក្រឡេកមើលទៅរថយន្តទេសចរ ក៏ឃើញយានយន្តបញ្ឈប់ ដោយឃើញស្រស់តរុណីឈរបង្ហាញ



រាងយ៉ាងជ្រងោប្របមាត់ទ្វារយាន ។

អ្នកកម្លោះភ្ញោចខ្លួន ស្ទុះក្រោកឈរទាំងអរកខិបកខុប ហើយរលាស់ស្មាស្ពាយកាបូបតាមសម្រួល ទើបប្រញ្ញប្រញាប់ដើរលឿនខ្ទឹតមកកាន់រថយន្ត ។ នៅពេលដើរមកដល់ទល់មុខឆោមល្អ ថាវរៈក៏ញាក់មុខ ហើយបោះសម្ដីឡេះឡោះ បែបកំហិល :

- ចេះមានកូនចិត្ត អាណិតអន្ទាក់អន្ទិចដែរតើ...! អរគុណណាស់ ស្រីស្រស់ប្រិមប្រិយ...!

នាងក្រមុំបើកភ្នែកសម្លក់ឡើងលៀនត្លៃ ទើបធ្វើបបូរមាត់ស្ពែះសងសម្ដីមកវិញ :

- អញ្ជើញឡើងឱ្យលឿនទៅ កុំប៉ប្លូចឥតប្រយោជន៍នោះ...! គៅអីគេអង្គុយពេញអស់ហើយ អញ្ជើញឈរចុះ...! ប៉ុន្តែបើរង៉ាក់រង៉ើកខ្យល់ចាប់តាមផ្លូវ គ្មានអ្នកណាគេជួយទេ បើមាត់ដាចដូចត្រីកំភ្លាញអញ្ចឹងនោះ...!

នរៈបោះជំហានឡើងមកលើរថយន្ត ទាំងងាកមុខមករកស្រស់មាណវី :

- បានឱ្យដោយសារ នេះពិតជាភ័ព្វសំណាងរបស់កម្លោះមុខមានមន្តស្នេហ៍ទៅហើយ...!

ថាវរៈនិយាយទាំងលាយសំណើច ធ្វើឱ្យអ្នកទេសចរទាំងអស់សើចក្អៀកហើយកញ្ញារ័តន៍ទាញទ្វារយានបិទបណ្ដើរ ដើរឡើងមកទម្លាក់បង្អុយជិតកុសល ដែលកំពុងបញ្ជាយានចេញដំណើរបន្ត ដោយអង្គុយបែរមុខមករកអ្នកទេសចរ រួចពេបមាត់រអ៊ូទាំងងើយមុខមើលមកនរៈកំពុងឈរតោងរបារដែកយាន :

- មុខមានមន្តស្នេហ៍...! មុខខ្មៅព្រិក ហើយហើមស្ប៉ុល ដូចមុខពូកប្រមឹក ក៏ចេះប្រឹងអួតកើតដែរ...! ប្រហែលជាមិនដែលឆ្លុះកញ្ចក់ មើលមុខខ្លួនឯងទេដឹង...!

កម្លោះមាត់ឆៅញាក់ចង្កេះឈរដោះកាបូបមកកាន់យួរ ហើយញាក់មុខមកកាន់នាងក្រមុំ :

- ចេះតែថាហើយ...! មុខខ្ញុំនេះ មុខឡូយ មុខស៊ីលុយណា...! មើល៍១មុខខ្ញុំពេលញញឹមមានខួចម្ខាងផង...! ម៉េចកម្លោះថ្ពាល់ខួចអញ្ចឹង ញញឹមស្រស់ទេ...?

ថាវរៈធ្វើឫកជាខំញញឹមបង្ហាញថ្កាល់ខូច ដូចបណ្ដាលឱ្យអ្នកទេសចរនាំគ្នាសើចខឹកៗ ហើយកញ្ញារ័តន៍ខាំមាត់រលាស់សម្ដី :

- នែ៎លោក...! សូមមាត់លោកនៅឱ្យស្ងៀមខ្លះផងបានទេ...? បើលោកចង់ញញឹមបង្ហាញថ្កាល់ខូច សូមអញ្ជើញចុះទៅញញឹមបង្ហាញសម្រស់អួតប្រាប់មេឃ ប្រាប់វាលស្រែចុះ...! ឡានខ្ញុំមិនត្រូវការដឹកមនុស្សច្រឡឹមឡើងហៀរខ្លាញ់ដូចលោកទេ...! ច្រឡឹមអីក៏ច្រឡឹមម្ល៉េះ...!

នរៈសើចហ៊ែសៗ ធ្វើឫកខែងរ៉ែង ទាំងញាក់ស្មា :

- អស់ពីតាប៉ិមុខជម្ម មកកម្លោះថ្មើមយោល...! ដល់ឥឡូវលោកច្រឡឹមហៀរខ្លាញ់...! ពីរោះម្យ៉ាងដែរ តែបើផ្សំពាក្យរួមបញ្ចូលគ្នាទៅ...! អីយ៉ាលោកតាប៉ិកម្លោះ...! ពិតជាពីរោះផស់គេមែន...! ប្រសប់ហៅណាស់តើនេះ...!

អ្នកទេសចរគិតតែពីនាំគ្នាសើចកាច់កកាច់ស្រង់ ឯកុសលវិញធ្វើមុខស្មឿក ហាក់រញ៉េរក្នុងចិត្ត ក៏ងាកមកសម្លក់ថាវរៈ ហើយស្រដីមកកាន់ស្រស់ស្រី :

- យី...! មិនចេះរួយមាត់សោះ...! បានហើយកញ្ញារ័តន៍...! ចំណែកលោកឯងក៏សមល្មមឈប់ប៉ិចាច់ប៉ិចោចទៀតដែរ...! ខ្ញុំវិញខំស្ដាប់យូរៗទៅ ឡើងសង្កៀរត្រចៀកទៅហើយ...!

ថាវរៈលើកថង់អាពីងយូរស្ដោក ហើយសើចស្ញេញ :

- សុំទោសៗ...! ពីរោះមែនហ្ន៎កញ្ញារ័តន៍...! ឈ្មោះនេះពិតជាសមនឹងរូបសម្បត្តិខ្លាំងណាស់...! កញ្ញារ័តន៍ៗ ឱ...! កញ្ញារ័តន៍...! កញ្ញារ័តន៍ឈ្មោះនេះពីរោះអស្ចារ្យមែន...!

នាងក្រមុំស្ទុះក្រោកឈរ ទាំងខឹងឡើងក្រហមមុខដូចផ្លែទន្លាប់ទុំ :

- ស្ងៀមទៅលោក...! ទន្ទេញអីក៏ទន្ទេញម្ល៉េះ មើលតែមិនដែលឮឈ្មោះនេះ...!

- បើមែន ឱ្យខ្ញុំទន្ទេញឈ្មោះនេះផងមិនបានអ្វី កញ្ញារ័តន៍...?

ទាល់តម្រិះឆោមស្រស់ក៏ទម្លាក់គូថអង្គុយចុះ ហើយងាកមុខចេញទាំងរអ៊ូរទាំៗ :

- ភ្នែកលលាម មាត់រឡាញ មិនដែលឃើញទេលោកអើយ...! ប្រហែលជាមាន



តែម្នាក់ទេមើល៍ទៅ ម៉ាជីខ្មែរ...! រឡិបរឡប់មើល៍តែមនុស្សពុលទឹកមាត់...!

កុសលគ្រវីក្បាលក្ដៅក្រហាយ ក៏ប្ដូរលេខបន្ថែមល្បឿនយានយ៉ាងរហ័ស រថយន្តក៏ស្ទុះកញ្ឆក់ទៅមុខ បណ្ដាលឱ្យថាវរៈដែលកំពុងឈរប្រយិតប្រតោងនោះ ស្ទើរតែត្រូវដួលដាច់ផ្ងារទៅក្រោយ ។ ប៉ុន្តែស្របពេលនោះ បងប្រុសម្នាក់ក៏ងើបដោលខ្លួនមកជួយទប់ប្រាណនរៈឱ្យឈរតាមសម្រួល ។ ថាវរៈទប់ជំហរបានស្រួលបួល ទាំងលបរអ៊ូរទាំនៅក្នុងចិត្ត... " យី...! អាតៃកុងឡាននេះ ប្រច័ណ្ឌនឹងយើងទេដឹង បានជាបើកឡានកញ្ឆក់កញ្ឆែងខុសបទយ៉ាងហ្នឹង...? នែ៎ៗ អនិតសាច់ស្នេកសស្លាំង មើល៍តែពូកចាញ់បរអើយ កុំសង្ស័យថាបានកញ្ញារ័តន៍ធ្វើជាគូនោះ...! ប្រហែលជាដេកយល់សប្តិ ដូចឆ្មាដេកក្នុងផេះកណ្ដាលចង្ក្រាន ចាំអង្កៀមឆ្អឹងត្រីអាំងទេដឹង ណាអនិតឆ្មាផេះ...! មើល៍មុខ ដល់ខឹងក្រញ៉េតអញ្ចឹងទៅ មិនខុសពីមុខបងស្វា ត្រូវនាយខ្លាចងកន្ទុយអូសធ្វើមាត់ស្ញេញ ដូចក្នុងរឿងសុភាទន្សាយនោះឡើយ...! ប្រឹងខឹងច្រឡោតតោតតូងទៅអនិតអើយអនិត ប្រហែលបានត្រឹមតែលាភរនិតទេមើល៍ទៅ...! កុំធ្វើឫកហាំហួន ថាខ្លួនហ៊ីហាននោះ ឥតប្រយោជន៍ទេ...! " ។

ថាវរៈលបសើចខឹកៗតែម្នាក់ឯង ហើយបែរមុខសម្លឹងទៅក្រុមអ្នកទេសចរដែលនាំគ្នាសើចដែរនោះ រួចនរៈងាកមកសម្លឹងមុខនាងក្រមុំ ក៏ឃើញឆោមល្អក្ដាប់មាត់សម្លក់មកស្ទើរជ្រុះគ្រាប់ភ្នែក ទើបអ្នកកម្លោះថ្កាល់ខូចញាក់ចិញ្ចើមឈរសម្ងំស្ងៀម ទាំងនៅសើចញឹមៗ ។

កំពុងសម្ងំឈរស្ងូក ស្រាប់តែទូរស័ព្ទក៏រោទិ៍រន្ថើនឡើង ទើបថាវរៈលូកទាញទូរស័ព្ទមកនិយាយ ទាំងធ្វើភ្នែកម៉ក់ៗ សម្លឹងមកស្រស់ស្រី :

- អាឡូ...! ឯងមកដល់ណាហើយហ្នឹង...? យើងកំពុងជិះឡានទេសចរជាមួយជួបនឹងស្រីស្អាតម្នាក់ពូកែសម្ដី កាចឆ្នាស់ដូចរាជិនីឪម៉ាល់អញ្ចឹង...! អើៗ បើកឱ្យស្រួតម៉ោ យើងគង់តែជួបគ្នាទេ...! ផ្លូវតែមួយ ជាន់លេខមួយរយៗម៉ោណា...! យើងខ្លាចរាជិនីឪម៉ាល់ ទិចយើងណាស់វើយ...!

កម្លោះមាត់ឆៅនិយាយបណ្ដើរ ធ្វើភ្នែកស្រឡេវដូចមនុស្សស្រលៀងភ្នែកដាក់នាងក្រមុំ រួចបិទទូរស័ព្ទ ហើយរុញចូលហោប៉ៅខោ រួចសម្ងំឈរតាមសភាពដូចដើម ។

រថយន្តទេសចរចេះតែលូនរំកិលទៅមុខ សភាពស្ងប់ស្ងៀមនៅក្នុងយាន ក៏ចេះតែស្ងាត់ច្រៀប ហើយអ្នកទេសចរខ្លះក៏ចាប់ទន់ត្របកភ្នែក ស្ងាបហាម១ម្ដង១រកកលងងុយគេង ។ ចំណែកថាវរៈ ចាប់ផ្ដើមស្រពន់ជើង ស្រយង់ដៃ រួយចង្កេះ ស្ទើរតែទន់ជង្គង់ដួលម្ដង១ទៅហើយ ប៉ុន្តែនរះស៊ូទ្រាំឈរបានបន្តិច ក៏បន្ទន់ខ្លួនអង្គុយពែនភ្នែនប៉ប៉ុកនៅលើយានត្រង់ចន្លោះផ្លូវដើរ ដោយលើកកាបូបមកដាក់លើភ្លៅ ហើយដៃម្ខាងទៀតនៅតែកាន់ថង់ផ្ទុកសត្វអាពីង ។

កញ្ញារ័តន៍លបសើចញឹម១..." ស្មានថាគ្រាន់ ចេះអង្គុយដែរតើ..! មើលមុខកម្លោះពព្រើតពព្រើមហ្នឹងយូរ១ទៅ គួរឱ្យអស់សំណើចម្យ៉ាងដែរ...! ឱ... នែ៎... កម្លោះព្រួល១ធ្វើឫកព្រើល ភ្នែកស្លឹសព្រោងអើយ មុខហ្នឹងសមតែញុំព្រោនផ្ទុំគ្លិនព្រាំ សាច់ហើមព្រួក១ទេទើបឈប់ព្រួសសម្ដី លែងស្ដីព្រហើន ហើយច្បាស់ជារត់ចូលព្រៃទាក់ដើមព្រិច ដោយរុយរោមពព្រុយតាមរំខានតាំងពីព្រឹកព្រលឹមដល់ព្រលប់ សមមុខលោកតាប៉ិកម្លោះឯងមិនខាន...! បើអោកន្លះខាច់មែននោះ ប្រហែលជាខ្ញុំដេកសើចទាល់តែចុកពោះហើយ...! "។

នាងក្រមុំទប់សំណើចមិនបាន ក៏ផ្ទុះសំនូរលាន់ឃឹក១ ធ្វើឱ្យកុសលកំពុងបញ្ជារថយន្តងាកមកសម្លក់ ដោយស្រដី :

- ចេះសើចកក្អឹក តែម្នាក់ឯងទៅកើតដែរ...! ប្រហែលជាមិនដល់អង្គរផងឡប់តាមផ្លូវទេដឹង...?

- តែផ្កាស...! សម្ដីឆ្កួត១អញ្ចឹង ក៏ហាទៅរួចដែរបងកុសលនេះ...!

កុសលសើចញឹម១ ចេះតែបញ្ជាយានឱ្យរត់ដំណើរទៅមុខ ។ ស្រស់តរុណីអង្គុយស្ងៀម ដោយលបសម្លឹងមកថាវរៈផ្សៀក១ ។ ស្របពេលនោះ អ៊ំប្រុសម្នាក់ក៏បង្ហើរសម្ដីដូចតប់ប្រមល់ក្នុងអារម្មណ៍ :

- នាងតូចអើយ អីក៏ស្ងាត់ឈឹងម្ល៉េះ១...! កុំម្លឹង១ពេក មើលសាកនិទានរឿងព្រេង រឿងប្រវត្តិសាស្ត្រខ្មែរយើងខ្លះ១ទៅមើល៍...! អ៊ំឯណោះ អផ្សុកអប្បសាន្តឡើងទល់ពុទ្ធោទៅហើយ...!



បងស្រីម្នាក់ទៀត ក៏អន្ទោកអន្ទោល ទាំងសើចញញឹមញញែម :

- អាត់តែជជែកតវ៉ាគ្នាជាមួយលោកប្អូនខាងណោះ ភ្លេចពួកយើងអស់រលីង...! មើល៍ប្អូនស្រីនិយាយរឿងរ៉ាវភូមិស្រុកយើង ឱ្យបងបានស្ដាប់ខ្លះផងទៅមើល៍...! ពួកយើងម្នាក់១សប្បាយចិត្តណាស់ កាលបើបានដើរទេសចរណ៍ជាមួយប្អូនស្រី ដែលធ្វើជាអ្នកនាំផ្លូវរូបស្អាតអញ្ចឹង...!

- ចំណែកខ្ញុំវិញ...! អ៊ូយ... ម៉្ងៃ១ឮតែចម្រៀង ឃើញតែកុនបរទេសស្ទើរតែគ្រប់ប៉ុស្ដិ៍ទូរទស្សន៍...! យូរ១ទៅ ខ្ញុំនេះស្ទើរតែឡប់សតិនឹងចម្រៀង និងកុនបរទេសទៅហើយ..! សូមបងស្រីនិយាយរឿងពង្សាវតារខ្មែរយើងឱ្យពួកយើងបានដឹងខ្លះទៅបងស្រី..!

ប្អូនស្រីម្នាក់នោះនិយាយបណ្ដើរ អើតកក់ផ្អឹម១មករកកញ្ញារ័តន៍បណ្ដើរ ធ្វើឱ្យថាវរៈសើចផ្សៀងក ដែលចំហមាត់ខំស្ដាប់មកយូរហើយ ក៏ជួយបន្ថែមសម្ដី ទាំងធ្វើភ្នែកព្រឹម១ :

- ហ្នំ...! បងប្អូនគាត់ចង់ស្ដាប់រឿងរ៉ាវស្រុកទេសយើងពីអតីតកាល យ៉ាងម៉េចយ៉ាងណានោះ សូមសាកថ្វីមាត់បន្តិចទៅមើល៍ បើអ្នកនាងជាមគ្គុទ្ទេសក៍ទេសចរទៅហើយនោះ..! លាក់ចំណេះធ្វើអី..! នៅច្រិមច្រុមអីទៀត..! មែនទេបងប្អូនអ្នកទេសចរ...?

ប្រយោគសំណួរចុងក្រោយរបស់ថាវរៈ បានធ្វើឱ្យអ្នកទេសចរទាំងអស់ សើចព្រមគ្នា :

- ត្រូវហើយ១...!! ចំណេះពេញខ្លួន មានទាំងប៉ុន្មាន បញ្ចេញឱ្យអស់ម៉ោ...!!

កុសលក៏សើច ងាកមកសម្លឹងមុខនាងក្រមុំ ដែលកំពុងសើចញឹម១ :

- បើបងប្អូនទទូចយ៉ាងហ្នឹង លេងម៉ាឈ្នះដៃទៅកញ្ញារ័តន៍...! បងក៏ចង់ដឹងថ្វីមាត់អូនឯងដែរតើ..! បើចុះសមរភូមិមិនប្រយុទ្ធទេ គេហៅថាជនកំសាកខ្លាចស្លាប់ណា..!

ឮពាក្យពន្យុះរបស់កុសល ក្រុមអ្នកទេសចរក៏ទះដៃហោប្រាវ១ ធ្វើឱ្យឆោមស្រស់

សើច ហើយបង្វែរខ្លួនអង្គុយតាមសម្រួល ដោយឈមមកអ្នកទេសចរទាំងនោះ ទើបជម្រុះសម្ដីមួយៗ :

- នាងខ្ញុំសូមអរគុណហើយ ដែលបានបងប្អូនទាំងអស់ មានចំណាប់អារម្មណ៍លើរឿងរ៉ាវស្រុកទេសយើងពីបុរមបុរាណ ហើយនាងខ្ញុំក៏សូមអរគុណជាពន្លឹកដែរ ដែលបងប្អូនបានផ្ដល់ឱកាសឱ្យនាងខ្ញុំបានអធិប្បាយខ្លីៗ ពីពង្សាវតារខ្មែរយើង...! នាងខ្ញុំសូមអធ្យាស្រ័យទុកជាមុន បើមានលើសលស់ ឬឆ្គាំឆ្គងម្ដេចម្ដា ជួយកែលំអដល់នាងខ្ញុំវិញផង...! នាងខ្ញុំចេះចាំប៉ុណ្ណា បកស្រាយប៉ុណ្ណោះ...!

ពូម្នាក់រាងតូចទ្រនាប់ សើចហ៊ីសៗ រួចបង្អើលវាចាកាត់ភ្លែត :

- មិនអីទេក្មួយស្រី...! ក្មួយស្រីនិទានចុះ ពួកយើងមិនចាប់ទោសអូសដំណើរទេ...! សម្ដីក្មួយស្រីពីរោះដូចសម្លេងសារិកាអញ្ចឹង ច្បាស់ជាធ្វើឱ្យពួកយើងខួបស្លឹកត្រចៀកប្រឹងស្ដាប់ពុំខាន...! លលេងសម្ដីទុកជាអនុស្សាវរីយ៍ នៅពេលធ្វើទេសចរណ៍នេះចុះក្មួយស្រី...! ខ្លាចរអាស្អីក្មួយ...!

ថាវ៉ៈញាក់ចិញ្ចើមពព្រើត ខំញញឹមពព្រាយ ទាំងវាយពាក្យពេចន៍ :

- សម្លេងពីរោះដូចសត្វសារិកាអញ្ចឹង បើឱ្យខ្ញុំបានស្ដាប់ពិតជាមិនធុញទ្រាន់ទេ..!

នាងក្រមុំចងចិញ្ចើមសម្លក់មកអ្នកកម្លោះ រួចសើចប៉ប្រិម មកកាន់ក្រុមអ្នកទេសចរ :

- មុននឹងនាងខ្ញុំនិយាយពីប្រវត្តិសាស្ត្រខ្មែរ នាងខ្ញុំសូមបើករង្វង់ក្រចកបន្តិច...! នាងខ្ញុំចង់និយាយថា បើបងប្អូនចង់បំបាត់ចម្ងល់ ចង់ដឹងពីរឿងរ៉ាវស្រុកទេស ជាពិសេសប្រវត្តិរឿងរ៉ាវផ្សេងៗ ដែលទាក់ទងជាមួយប្រវត្តិភូមិស្រុក ប្រាសាទ ព្រះមហាក្សត្រ សាសនា និងប្រពៃណីទំនៀមទម្លាប់របស់ខ្មែរយើង...! បងប្អូនអាចឆ្លៀតពេលបន្ធូរអារម្មណ៍ពីការនឿយហត់ ពីការធុញទ្រាន់នឹងការស្ដាប់ចម្រៀង ពីការមើលកុនបរទេស ដោយរើសពេលវេលាតាមសមគួរ មកអង្គុយអានកម្សាន្តនូវសៀវភៅផ្សេងៗ ដូចជាសៀវភៅប្រវត្តិសាស្ត្រ សៀវភៅមគ្គុទ្ទេសក៍នគរ សៀវភៅប្រលោមលោក និងសៀវភៅ



ដទៃទៀតឱ្យបានច្រើន ដើម្បីបង្កជាពុទ្ធិពង្រីកចំណេះដឹងទូទៅ យ៉ាងហោចណាស់ក៏ស្គាល់តម្លៃអក្សរសាស្ត្រជាតិ អក្ខរាវិរុទ្ធ អក្ខរក្រមជាតិ ព្រោះថាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ តាមសិលាចារឹកជាគោលតឹកតាង ពិតជាភាសាខ្មែរ អក្សរសាស្ត្រខ្មែរ យើងបាននិយាយ បានរៀនសូត្រនៅសព្វថ្ងៃនេះ...! បើទុកជាមានសភាពប្លែកខ្លះ តែដោយសម្លេងដែលយារក្លាយតៗគ្នាប៉ុណ្ណោះ...! ភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ មានបែបផែនល្អ ហើយចាស់ជាងគេ ក្នុងចំណោមជនជាតិនៅប្រទេសឥណ្ឌូចិន...! អ្នកណាដែលស្គាល់តម្លៃអក្សរសាស្ត្រជាតិ ដូចរូបគេបានស្គាល់តម្លៃនៃជីវិតខ្លួនយ៉ាងដូច្នេះ...! អក្សរសាស្ត្រជាតិ ជាដួងព្រលឹង ជាសាច់ ជាឈាមនៃខ្លួនប្រាណយើងគ្រប់ៗគ្នា...! បើយើងស្រឡាញ់អក្សរសាស្ត្រជាតិ ក៏ដូចជាយើងស្រឡាញ់ជីវិតខ្លួនយើងដូច្នោះដែរ...!

កញ្ញាវ័តន៍បង្អង់សម្លេង ធ្វើឱ្យក្រុមអ្នកទេសចរសើចហោដោយទះដៃលាន់សម្ដី :

- ពិតជាមានឧត្ដមគតិល្អណាស់ មគ្គុទ្ទេសក៍រូបស្អាត...!

- ពិតជាមានថ្វីមាត់ ពីរោះណែងណងអស្ចារ្យមែន...!

- ទាល់តែបញ្ចេញក្បួនឱ្យហ៊ឺកហ៊ាក់ហៅហានអញ្ចឹង ទើបបានដឹងថា ចំណាប់ចំនួនប៉ុណ្ណា...! ពិតជាបានទាំងរូប បានទាំងចំណេះមែនហើយ កញ្ញារូបស្រស់...!

ថាវ៉ៈសើចញឹមៗ ហាក់ពេញចិត្តជាខ្លាំងនូវសំនួនវោហាររបស់នាងក្រមុំ ហើយក៏ស្ទុះក្រោកឈរ ដោយធ្វើភ្នែកក្រឡើតក្រឡាប់ ទាំងរលាស់សម្ដី :

- ចំណេះក៏ខ្ពស់ ឈ្មោះក៏បាន ប្រាណក៏ឡូយ បើឱ្យខ្ញុំធ្វើឬកឡូយថ្វយខ្ចីខ្នាមិនតាមដានស្ដាប់ ច្បាស់ជាដេកមមើយំបោកខ្លួនសោកស្ដាយពុំខាន..! មែនទេកញ្ញាម្ទេសទុំ...?

អ្នកកម្លោះឡិមឡុមខំនិយាយទាំងញាក់ចិញ្ចើម បញ្ចេញឬកច្រឡឹម ធ្វើឱ្យនាងក្រមុំធ្វើមុខក្រញូសលែងស្រស់បស់ ហើយក្រោកឈរស្ទើតចង្អុលមុខ :

- ដេកមមើស្អី...? យំបោកខ្លួនសោកស្ដាយស្អី...? មាត់លោកឯង មានគម្របខ្លះផងទៅមើល៍...! មើល៍មុខមិនចេះញញួនទេ...!

- អីក៏ញញួញធ្មេញ ឆាប់ញៀវញ៉ាវម្ល៉េះ...! បើខ្ញុំញ៉េះញ៉ោះតែបន្តិចសោះ ម្ដេចក៏

ខំស្រែកញ៉ែចញ៉ាច ទាំងធ្វើឫកញិកញ៉ក់អញ្ចឹង...! កុំមើលមកខ្ញុំ ក្នុងផ្លូវអាក្រក់ខ្លាំងពេក ស្រីស្អាត...!

នៅពេលឃើញថាវរៈនៅតែងងើលឆ្លើយប៉ប៉ែះមកយ៉ាងដូច្នេះ កញ្ញារ័តន៍ក៏ទម្លាក់ខ្លួនអង្គុយ ទាំងក្តាប់មាត់រអ៊ូ :

- បើជួបមនុស្សធីៗនេះ ទម្រាំតែដល់សៀមរាប ច្បាស់ជារយៈទ្រូងស្លាប់មិនខានទេ...!

ភ្លាមនេះ បងស្រីម្នាក់ដែលកំពុងបំបៅកូននោះ ក៏ស្រែកឃាត់មកយ៉ាងរហ័ស :

- បានហើយលោកប្អូន...! លោកប្អូនឈប់ឡិមឡម ធ្វើឡកឡាក់ដាក់នាងអូនទៀតទៅ...! តាំងពីនៅផ្សារស្តន់ មកដល់ជិតកំពង់ធំទៅហើយ បងឃើញអ្នកទាំងពីរតមាត់ត-កត្តាឱ្យរហូត...! ប៉ុន្តែ បើបងមើលលោកប្អូន និងនាងអូនយូរៗទៅ ស័ក្តិសមគ្នាល្អឥតខ្ចោះហើយ...! ស្អាតសង្ហា ស្រស់សោភា មើល៍តែតារាឯកភាពយន្ត...! តិចលោក៏ជាគូព្រេងនិស្ស័យនឹងគ្នាទេដឹង បានជាមានសំណាងបានជួបគ្នានៅលើឡានទេសចរយើងនេះ...? បើអញ្ចឹងមែន នៅថ្ងៃរៀបការ សុំផ្ញើធៀបការអញ្ជើញពួកយើងចូលរួមផង...!

អ្នកទេសចរផ្អើលគឹលទះដៃហ៊ោកេ្រវ ធ្វើឱ្យថាវរៈលើកដៃរឹតដើមទ្រូងពេបមាត់:

- ឆ្ពាសឆ្អើមយ៉ាងនេះ មិនធានាខ្លួនយកក្លិនទៅផ្ញើទេ...! ប្រហែលជាគ្មាននិស្ស័យទៅជាមួយឡើយ...!

ឆោមស្រស់ត្រញ៉ែងខ្លួន បើកភ្នែកធំ ខាំមាត់សម្លក់ :

- ជម្លើយខុសបទ ស្បថប្រាំពីរវត្ត មិនឱ្យជួបទេមនុស្សធីនេះនុ៎ះ...! លលីមលលាម មាត់ឆៅ មើលតែកូនសិស្សរៀននៅក្រៅសាលា ក្រៅថ្នាក់...!

ថាវរៈបម្រុងតបតទៅវិញ ធ្វើឱ្យកុសលដែលសម្ងំស្តាប់ជាយូរមកហើយ ក៏ទ្រាំស្ងៀមមិនបាន ក៏ងាកមុខមកទាំងក្តៅក្រហល់ក្រហាយក្នុងចិត្ត :

- បើអូនឯងដឹងថា គេជាសិស្សក្រៅថ្នាក់ទៅហើយ ចាំបាច់អីអូនឯងនៅសាំញ៉ាំជាមួយទៀត...? បងទើសចិត្តដល់ហើយនេះ...! សង្ឃឹមចាប់ផ្តាយលើមេឃចុះ ប្រហែលជាគ្មានវាសនាទេ...!



កុសលបោះផ្លែសម្តីឌឺដងមកថាវរៈ នាំឱ្យកញ្ញារ័តន៍សើចត្រហាញ ហើយអ្នកទេសចរចេះតែនាំគ្នាសើចកក្អឹក ។ នរៈទម្លាក់ដៃមកក្តោបកាបូបយួរជាមួយថង់សត្វអាពីង ទាំងលបរអ៊ូក្នុងចិត្ត... " យ៉ើ...! ខំបញ្ចេញក្បាច់ ការពារនាងក្រមុំម្ទេសទុំនេះណាស់តើ...! ហេងស៊ីស៊ីយទេ ណាអន្និតសកញ៉ូក បើយើងទាល់ច្រក តាមដណ្តើងនាងច្រមក់នេះឱ្យខាងតែបាន...! ចាំមើល៍ចុះ តើដៃអ្នកណារហ័សជាងដៃអ្នកណា...? គេថាបើពិតជាគូព្រេង នៅមិនឆ្ងាយតឹក្បែរច្រមុះសោះ...! " ។

នៅពេលនោះ ក៏ឃើញលិខិតបញ្ជារថយន្តមកទាន់រថយន្តទេសចរដែលកំពុងរត់ដំណើរលើវិថី ហើយលិខិតក៏បើកវ៉ាបង្ហួសមកពីមុខ ធ្វើឱ្យថាវរៈបានឃើញយានមិត្តសម្លាញ់ ក៏សើចប៉ប្រិម ទាំងញាក់ចង្កេះ វលាស់សម្តី :

- អរគុណៗ...! សូមអរគុណហើយ ដែលស្រីស្អាតឱ្យខ្ញុំបានជិះឡាន បានជម្លោះជាមួយ...! ឥឡូវនេះខ្ញុំឈប់ជម្រេញស្រីស្អាតទៀតហើយ...! នុ៎ះៗ... ឡានពួកម៉ាកខ្ញុំមកទាន់ហើយ...! សូមៗលោកតៃកុងដៃឯក ជួយឈប់ឡានអន្ទាក់អន្ទិចទៅមើល៍...!

កុសលត្រវីក្បាលនឹងសម្តីនរៈកំហិល ហើយចាប់ហ្វ្រាំងយានយឺតៗ ធ្វើឱ្យរថយន្តឈប់នឹងថ្កល់ ទើបថាវរៈលើកកាបូបមកស្ពាយ ដោយយួរថង់ផ្ទុកសត្វអាពីង រួចងក់ក្បាលមកគំនាប់ដល់ក្រុមអ្នកទេសចរ ទាំងបង្ហើរវាចាបណ្តើរ សើចញញឹមរីករាយបណ្តើរ :

- ខ្ញុំសូមជម្រាបលាអ្នកទាំងអស់នៅត្រឹមនេះហើយ...! សូមឱ្យអ្នកទាំងអស់ធ្វើដំណើរទេសចរណ៍ ប្រកបដោយសុវត្ថិភាព និងសប្បាយរីករាយចុះ...! ប៉ុន្តែប្រហែលជាជួបខ្ញុំនៅអង្គរទៀតផងមិនដឹង...! ខ្ញុំសូមលាហើយ តៃកុងឡានរូបឆើត ក្រមុំរូបស្រស់...! ថ្ងៃក្រោយជួបគ្នា...!

ក្នុងខណៈនោះ ឆោមស្រស់ដើរចុះមកបើកទ្វារយានចំហធ្លុង ទាំងពេបមាត់ឡងសម្តី :

- អញ្ជើញទៅឱ្យផុតស្រឡះចុះ កម្លោះថ្លើមយោល...!

នរៈសើចខឹក១ ហើយឈរវលាស់រាងអន្ទើត១ ទើបលើកដៃលាក្រុមអ្នកទេសចរ រួចដើរចុះមកក្រោម ទាំងញោចស្មាចេញផ្កាញញឹម :

- ទាល់តែមានសុជីវធម៌ល្អឥតបីអញ្ចឹង ទើបគេហៅថាកូនស្រីគ្រប់លក្ខណ៍...! ប៉ុន្តែយប់នេះ សូមស្រីស្អាតកុំដេកមមើនឹកមមៃស្រមៃដល់ខ្ញុំឱ្យសោះណា...! តិច១ ដេកយល់សប្តិឃើញកម្លោះថ្កាល់ខូចមួយនេះ ខ្ញុំច្បាស់ជាហើមពោះស្លាប់មិនខានទេ...!

- មុខដូចជ្រូកឈើអញ្ចឹង...! ជេះ...!!

បញ្ចប់វាចាភ្លាម នាងក្រមុំក៏ទាញបន្ទះទ្វារយានបិទលាន់គ្រាំង ថាវរៈក៏ដកខ្លួនថយ ហើយឈរលើកដៃគ្រវីលា ដោយរថយន្តទេសចរលូនចេញទៅសន្សឹម១ ទើបអ្នកកម្លោះមុខស្រស់រំកិលជំហានមករកមិត្តសម្លាញ់ដែលឈរអែបនឹងរថយន្ត ទាំងសើចក្អាកក្អាយ ។ លិខិតឃើញថាវរៈសើចស្ងេញស្ងាញដូច្នេះ ក៏គ្រវីក្បាលសើចដោយងើយមើលមេឃខៀវស្រឡះ ដូចរសាយអស់នូវទុក្ខកង្វល់ ។

Khmer Story Lovers